# ការណែនាំ និងការចម្លងរោគ៖ ជំងឺរលាកថ្លើមប្រភេទ B

**ជំងឺរលាកថ្លើមប្រភេទ B គឺជាមេរោគដែលបណ្តាលឱ្យរលាកថ្លើម។ យូរៗទៅការរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ (រយៈពេលយូរ) បណ្តាលឱ្យមានស្លាកស្នាម និងការខូចខាតថ្លើម។ នេះបង្កើនហានិភ័យនៃជំងឺមហារីកថ្លើម និងការខ្សោយថ្លើម។**

**គេមិនអាចព្យាបាលជំងឺរលាកថ្លើមប្រភេទ B បានទេ ប៉ុន្តែគេអាចគ្រប់គ្រងវាបាន ដើម្បីកាត់បន្ថយហានិភ័យនៃការខូចថ្លើម។ មានវ៉ាក់សាំងដ៏មានប្រសិទ្ធភាពដើម្បីការពារជំងឺរលាកថ្លើមប្រភេទ B។**

**ការចម្លងជំងឺរលាកថ្លើមប្រភេទ B កើតឡើងតាមវិធីបីយ៉ាង៖**

### 1. ពីម្តាយ ទៅទារក

ប្រសិនបើស្ត្រីមានផ្ទៃពោះរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B ហានិភ័យនៃការចម្លងរោគទៅទារកគឺមានខ្ពស់ណាស់។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងការថែទាំអ្នកឯកទេសល្អ ហានិភ័យអាចត្រូវបានកាត់បន្ថយយ៉ាងខ្លាំង។ នេះអាចរួមមានថ្នាំព្យាបាលសម្រាប់ម្តាយក្នុងអំឡុងពេលមានផ្ទៃពោះ ព្រមទាំងការចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B ហើយនិងការចាក់វ៉ាក់សាំងមួយទៀតហៅថា immunoglobulin សម្រាប់ទារកភ្លាមៗបន្ទាប់ពីកំណើត តាមដែលអាចធ្វើទៅបាន។

### 2. ពីឈាមទៅឈាម

កត្តាហានិភ័យនានារួមមានការប្រើប្រាស់ឧបករណ៍ចាក់ម្ជុលរួមគ្នា និងការប្រើប្រាស់ឧបករណ៍សាក់ស្បែក និងចោះស្បែកដែលមិនរម្ងាប់មេរោគ។

### 3. ការឆ្លងនៅពេលរួមភេទ

ជំងឺរលាកថ្លើមប្រភេទ B អាចឆ្លងតាមរយៈការរួមភេទដោយមិនបានប្រើស្រោមអនាម័យ។

មានវ៉ាក់សាំងដែលមានសុវត្ថិភាព និងប្រសិទ្ធភាព ដែលការពារអ្នកពីការឆ្លងជំងឺរលាកថ្លើមប្រភេទ B។ វាមានប្រសិទ្ធភាព ប្រសិនបើអ្នកបានចាក់វ៉ាក់សាំងមុនពេលប៉ះពាល់តែប៉ុណ្ណោះ។ សម្រាប់មនុស្សពេញវ័យ ត្រូវមានការចាក់វ៉ាក់សាំងបីដង ក្នុងរយៈពេលប្រាំមួយខែ។

LiverWELL
Incorporating HEPATITIS VICTORIA

GILEAD
Supported by a grant from Gilead Sciences